ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

...ៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
...ធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

លេខ: ៥៥៣៧ លខ.គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៧

**គោរពជូន**

**ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ** ៖ សេចក្តីណែនាំក្នុងការរៀបចំបញ្ជីឈ្មោះអ្នកទទួលការលទ្ធកម្មគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៨។

**យោង** ៖ -សេចក្តីសម្រេចលេខ ០០១ សសរ/គ.ជ.វ.វ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ២០០៩ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។

-សេចក្តីជូនដំណឹងលេខ ០៤៥ សជណ/គ.ជ.អ.ប ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០១០ និងសេចក្តីជូនដំណឹង ០៧៦ សជណ/គ.ជ.អ.ប ចុះថ្ងៃទី ០៤ ខែកក្កដា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នូវគោលការណ៍ណែនាំថ្មីមួយចំនួនស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវមេត្តាជ្រាបថា៖ សៀវភៅ ណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០០៩ (PIM) តម្រូវឱ្យរាជធានី ខេត្តរៀបចំបញ្ជីឈ្មោះអ្នកទទួលការប្រចាំ ឆ្នាំបានចប់សព្វគ្រប់មិនឱ្យហួសពីថ្ងៃទី ៣១ ខែធ្នូ។ ដំណើរការនេះ ត្រូវចាប់ផ្តើមពីការបង្កើតគណៈកម្មការបុរេលក្ខណៈសម្បត្តិអ្នកទទួលការ និងការប្រកាសស្តីពីការដាក់ពាក្យចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកទទួលការឆ្នាំ២០១៨ តាមរាជធានី ខេត្ត នីមួយៗ តាមទម្រង់ទី២៣ ដែលការប្រកាសនេះមិនត្រូវឱ្យយឺតជាងថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០១៧ ឡើយ និងត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ ជាពិសេសត្រូវបិទផ្សព្វផ្សាយលើក្តារព័ត៌មានរបស់សាលារាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។ ដោយសារមានភាពមិនប្រក្រតីក្នុងការរៀបចំបញ្ជីឈ្មោះអ្នកទទួលការក្នុងខេត្តមួយចំនួនកន្លងមក លេខាធិការដ្ឋាន គ.ជ.អ.ប ស្នើសុំគណៈកម្មការបុរេលក្ខណៈសម្បត្តិរាជធានី ខេត្តយកចិត្តទុកដាក់ និងពង្រឹងនីតិវិធី រៀបចំបញ្ជីឈ្មោះអ្នកទទួលការចាប់ពីការទទួលពាក្យស្នើសុំ ក៏ដូចជាការវាយតម្លៃគុណភាពគម្រោង គ្រឿងចក្រ និង បុគ្គលិកដល់ទីកន្លែង ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងការប្រកួតប្រជែង។ ដំណើការ និងនីតិវិធីនៃការរៀបចំបញ្ជីឈ្មោះអ្នកទទួលការ មានចែងលម្អិតក្នុងជំពូក ៣ ចំណុច ៣.២ នៃសៀវភៅ PIM។

រាជធានី ខេត្តត្រូវផ្ញើជូនលេខាធិការដ្ឋាន គ.ជ.អ.ប នូវបញ្ជីឈ្មោះអ្នកទទួលការទម្រង់៣១ និងបញ្ជីខ្មៅអ្នកទទួលការទម្រង់៣២(បើមាន) បន្ទាប់ពីចុះហត្ថលេខាដោយអភិបាលរាជធានី ខេត្តសាមី ដើម្បីប្រកាសផ្សាយជាសាធារណៈនៅគេហទំព័ររបស់លេខាធិការដ្ឋាន គ.ជ.អ.ប។

អាស្រ័យដូចបានជម្រាបជូន សូម **ឯកឧត្តម លោកជំទាវ**ចាត់វិធានការតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ប្រកបដោយ ប្រសិទ្ធភាពខ្ពស់។

សូម **ឯកឧត្តម លោកជំទាវ**ទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**
**...ប្រធានប្រតិបត្តិ**

ប៉ាង ប៉ូរ៉ា

អាសយដ្ឋាន: លេខាធិការដ្ឋាន គ.ជ.អ.ប ក្រសួងមហាផ្ទៃ ។ ទូរស័ព្ទ: (៨៥៥-២៣) ៧២០ ០៦១/៧២០ ០៣៥ E-mail: info@ncdd.gov.kh Website: www.ncdd.gov...